ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាស៊ើបសួរ

លេខ ៣០៨

ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១៧

សាលដីកា

លេខ: ៨៨"ក្រVI.អប"

ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងច្បាប់ស្តីពី ការរៀបចំអង្គការតុលាការដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤ /០១៥ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាអសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៧ ដែលមានសមាសភាពដូចខាងក្រោម:

### សមាសភាពក្រុមប្រឹក្សា

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

កញ្ញា [redacted] ព្រះរាជអាជ្ញា

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងសភាស៊ើបសួរលេខ ៣០៨ ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១៧ ដែលមាន:

-ជនត្រូវចោទឈ្មោះ [redacted] គួន ភេទស្រី អាយុ ៥១ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតនៅភូមិទេពមន្ត្រី ឃុំព្រះរស់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល លំនៅបច្ចុប្បន្ននៅភូមិ [redacted] ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted]) នៅរស់ ប្រពន្ធឈ្មោះ [redacted] មានកូន ០៣នាក់ ទោសពីមុន គ្មាន ។

មានមេធាវី [redacted] លឹមហួរ ការពារសិទ្ធិឲ្យ ។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: ឆបោក ប្រព្រឹត្តនៅភូមិព្រះប្រសប់ ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តោ ភេទស្រី អាយុ ៧០ឆ្នាំ លំនៅបច្ចុប្បន្ននៅភូមិព្រះប្រសប់ ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

មានមេធាវី យូ ឧស្សាហ៍ ការពារសិទ្ធិឲ្យ ។

**អង្គហេតុដាក់ឲ្យស្ថិតក្រោមការពិនិត្យមានដូចតទៅ**



Scanned by CamScanner

នៅអំឡុងឆ្នាំ២០១០ ឈ្មោះ [redacted] គួន បានទៅខ្ចីប្រាក់ពីឈ្មោះ [redacted] គោ ជាបន្តបន្ទាប់រហូតដល់សព្វថ្ងៃនេះដោយក្នុងមួយថ្ងៃឈ្មោះ [redacted] គួន តែងតែខ្ចីប្រាក់ពីឈ្មោះ [redacted] គោ ពី ២០០,០០០(ម្ភៃម៉ឺន)រៀល ទៅ ១០០(មួយរយ)ដុល្លារអាមេរិក មានថ្ងៃខ្លះក្នុងមួយខែ ឈ្មោះ [redacted] គួន បានទៅខ្ចីប្រាក់ពីឈ្មោះ [redacted] គោ ២០ ទៅ ២៥ដងក៏មាន ដោយឈ្មោះ [redacted] គួន បានប្រើប្រាស់ភាពក្លែងបន្លំសម្លេងរបស់ចៅកែស្រីរបស់ខ្លួននិយាយទូរស័ព្ទជាមួយ ឈ្មោះ [redacted] គោ ដើម្បីឲ្យខ្លួនបានប្រាក់ពីឈ្មោះ [redacted] គោ ហើយបានប្រាប់ឈ្មោះ [redacted] គោ ថា អស់ប្រាក់ប៉ុន្មានចៅកែខ្លួនជាអ្នកសងជំនួសទេ ។ ដោយជឿតាមពាក្យបោកបញ្ឆោតរបស់ ឈ្មោះ [redacted] គួន ឈ្មោះ [redacted] គោ បានប្រគល់ប្រាក់ឲ្យឈ្មោះនេះជាបន្តបន្ទាប់ចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ។ លុះដល់ថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោង ០៧ ព្រឹក បានប្រើល្បិចបោកបញ្ឆោតដើម្បីខ្ចីប្រាក់ពីឈ្មោះ [redacted] គោ ចំនួន ២០០,០០០(ម្ភៃម៉ឺន) រៀល និងនៅម៉ោង ១៦ និង០០នាទីបានខ្ចីប្រាក់ចំនួន ១០០(មួយរយ)ដុល្លារអាមេរិកទៀត ។ ដោយមានការសង្ស័យឈ្មោះ [redacted] គោ ក៏បានណាត់ឈ្មោះនេះឲ្យមកយកលុយនៅចំណុច ភូមិព្រះប្រសប់ ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល និងក៏បានប្ដឹងសមត្ថកិច្ច ឲ្យធ្វើការឃាត់ខ្លួនឈ្មោះ [redacted] គួន តែម្ដង ។

-បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] គួន ឆ្លើយនៅចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកណ្ដាលថា: កាលពីថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៧ ខ្លួនបានទៅផ្ទះរបស់ ឈ្មោះ [redacted] គោ ដើម្បីទៅរកខ្ចីលុយឈ្មោះ [redacted] គោ ចំនួន ១០០(មួយរយ)ដុល្លារអាមេរិក បន្ថែមទៀត ប៉ុន្តែមិនទាន់ទទួលលុយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្ដង ។ កន្លងមកអំឡុងឆ្នាំ ២០១០ ខ្លួនបានទៅចងការប្រាក់ពីឈ្មោះ [redacted] គោ ជារៀងរាល់ថ្ងៃ ដោយមានថ្ងៃខ្លះខ្លួនខ្ចី ចំនួន ១០០(មួយរយ)ដុល្លារអាមេរិក ទៅ ២០០(ពីររយ)ដុល្លារអាមេរិក ថ្ងៃខ្លះ ២០០,០០០(ម្ភៃ ម៉ឺន)រៀល ឬ ៣០០,០០០(សាមសិបម៉ឺន)រៀល ចំពោះការខ្ចីប្រាក់ ខ្លួនបានបន្តខ្ចីពីឈ្មោះ [redacted] គោ រហូតមកដល់សព្វថ្ងៃនេះ (រហូតមកដល់ថ្ងៃឃាត់ខ្លួន) ហើយមិនទាន់បានសងទាំង ប្រាក់ដើម និងការប្រាក់ដល់ឈ្មោះ [redacted] គោ វិញនេះទេ សរុបប្រាក់ដើមដែលខ្លួនខ្ចីមាន ចំនួន ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ។ ចំពោះការខ្ចីរាល់លើកគឺខ្លួនបានទូរស័ព្ទទៅ ឈ្មោះ [redacted] គោ ដោយបានកុហកថា មានគេឲ្យជួយរកលុយចងការ ទើបឈ្មោះ [redacted] គោ យល់ព្រមឲ្យខ្លួនខ្ចី ហើយខ្លួនបានបញ្ជាក់ថា ចាំពេលមានលុយ ទើបសងគាត់វិញ ។ សំណូមពរ សុំសងលុយជាខែ ដោយក្នុងមួយខែសុំសង ៣០០,០០០(សាមសិបម៉ឺន)រៀល ។

-បានឃើញចម្លើយ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] គោ ឆ្លើយនៅចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាលថា: ឆ្នាំ២០០៦ ឈ្មោះ [redacted] គួន បានមកខ្ចីប្រាក់ពីខ្លួន ចំនួន ០៤លើកសរុបទឹកប្រាក់ ៣,៥០០,០០០(បីលានប្រាំសែន)រៀល ហើយបង់ប្រាក់ការ បានតែបីខែប៉ុណ្ណោះ សរុបលុយ ២៥០,០០០(ម្ភៃប្រាំម៉ឺន)រៀល ។ ក្រោយមកចាប់ពីឆ្នាំ ២០១០ រហូតមកដល់បច្ចុប្បន្នឈ្មោះ [redacted] គួន បានមកខ្ចីចងការប្រាក់ពីខ្លួនម្ដង ២០០,០០ ០(ម្ភៃម៉ឺន)រៀល ម្ដង ១០០(មួយរយ)ដុល្លារអាមេរិក និងពេលខ្លះរហូតដល់ ២០០(ពីររយ)ដុល្លា



Scanned by CamScanner

អាមេរិក ដោយខ្ចីស្មើរជារៀងរាល់ថ្ងៃក្នុងមួយខែ ប្រហែល ២០ដង ។ តែឈ្មោះ [redacted] គួន មិនបានយកការប្រាក់ ឬដើមមកសងខ្លួនទេ បើគិតប្រាក់ដើមគឺប្រហែល ៥០,០០០(ប្រាំម៉ឺន) ដុល្លាអាមេរិក ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៨៥៦ដកសស/១៧ ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ១១៩៨ដក.ស.យខ ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ។

**បានឃើញ ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ១១៩៨ដក.ស.យខ ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

-ឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] គួន ជាបណ្តោះអាសន្នហើយយើងនឹងចេញដីកាបង្គាប់ឲ្យឃុំខ្លួន ដើម្បីអនុវត្តការឃុំខ្លួននេះ ។

ដីកានេះ ត្រូវបានមេធាវី [redacted]លឹមហួរ ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted] គួន សុំ ប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ១១៩៨ដក.ស.យខ ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ ពាក្យសុំដោះលែងឈ្មោះ [redacted]គួន ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៧ របស់មេធាវី [redacted]លឹមហួរ ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted]គួន ប្តឹងសុំទៅចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ពាក្យបណ្តឹងរបស់មេធាវី[redacted]លឹមហួរ ការពារសិទ្ធិជនត្រូវចោទឈ្មោះ គាត គួន ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៧ មកសាលាឧទ្ធរណ៍ ។

-បានឃើញ របាយការណ៍ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៧ របស់ចៅក្រមសាលាឧទ្ធរណ៍ ។

-បានឃើញ សេចក្តីសន្និដ្ឋានចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៧ របស់ព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## នាពេលពិភាក្សាដេញដោល

-ជនត្រូវចោទឈ្មោះ[redacted] គួន (អវត្តមាន)

-មេធាវី [redacted] លឹមហួរ ការពារសិទ្ធិឲ្យជនត្រូវចោទ (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] តោ (អវត្តមាន)

-មេធាវី [redacted] ឧស្សាហ៍ ការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី (វត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេប



Scanned by CamScanner

តំណាងមហាអយ្យការបានសន្និដ្ឋានកត់សម្គាល់ប្តឹងសុំថា ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿង និងក្រោយពីបានស្តាប់របាយការណ៍នៃរឿងមក យល់ឃើញថា បណ្តឹងឧទ្ធរណ៍របស់មេធាវី [redacted] លឹមហួរ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់យោងតាមមាត្រា ២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ជនត្រូវចោទឈ្មោះ [redacted] គួន ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៧ ពីបទ ឆបោក តាមបញ្ញត្តិមាត្រា ៣៧៧ និង មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ដែលកំរិតនៃការផ្តន្ទាទោសគិតពី ០៦ខែទៅ ០៣ឆ្នាំ គឺជាបទមជ្ឈិម ។ តាមបញ្ញត្តិមាត្រា ២០៩ កថាខណ្ឌ ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវលើសពីពាក់កណ្តាលអប្បរមានៃទោសដែលច្បាប់កំណត់ ដូចនេះ ការឃុំខ្លួនលើឈ្មោះ [redacted] គួន មិនត្រូវលើសពី ០៣ខែឡើយ ។ ការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទឈ្មោះ [redacted] គួន មានរយៈពេល ០៥ខែ គឺហួសកាលកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ ។ ហេតុដូចនេះ គប្បីក្រុមប្រឹក្សាសម្រេចតាមច្បាប់ ។

-មេធាវី [redacted] លឹមហួរ ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted] គួន បានកត់សម្គាល់ប្តឹងសុំថា ក្នុងអំឡុងឆ្នាំ២០០៦ ឈ្មោះ [redacted] គួន ដែលជាកូនក្តីខ្លួនបានខ្ចីចងការប្រាក់ពីឈ្មោះ [redacted] ឈ្មោះ [redacted] តោ ដោយគិតការប្រាក់ ៥% ហើយសន្យាថានឹងបង់ការប្រាក់ជូនឈ្មោះ [redacted] តោ ជារៀងរាល់ខែ ។ លុះមកដល់ឆ្នាំ២០១០ ឈ្មោះ [redacted] គួន បានទៅខ្ចីចងការប្រាក់ពីឈ្មោះ [redacted] តោ បន្ថែមដោយថ្ងៃខ្លះខ្ចីចំនួន ១០០(មួយរយ)ដុល្លាអាមេរិក ថ្ងៃខ្លះទៀត ២០០(ពីររយ)ដុល្លាអាមេរិក គិតតាមចំនួនដែលខ្លួនត្រូវការ ។ លុះរហូតមកដល់ថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៧ កូនក្តីខ្លួនបានទៅខ្ចីប្រាក់ពីឈ្មោះ [redacted] តោ ម្តងទៀត ប៉ុន្តែបែរជាត្រូវប៉ូលិសឃាត់ខ្លួន និងកសាងសំណុំរឿងបញ្ជូនមកតុលាការជាប់ចោទពីបទឆបោកទៅវិញ ។ ផ្អែកតាមអង្គហេតុនេះឃើញថា វាជាទំនាក់ទំនងរដ្ឋប្បវេណីសុទ្ធសាធដែលបង្ហាញពីសិទ្ធិ និងកាតព្វកិច្ចរវាងអ្នកខ្ចី និងអ្នកឲ្យខ្ចី ដែលពុំមានធាតុផ្សំបទល្មើសណាមួយកំណត់បានថា ជាបទល្មើសព្រហ្មទណ្ឌបានឡើយ ។ កូនក្តីខ្លួនជាជនជាតិខ្មែរ មានក្រុមគ្រួសារ មានមុខរបរ និងមានទីលំនៅពិតប្រាកដ ហើយកូនក្តីខ្លួនជាបុគ្គលពុំដែលធ្លាប់មានទោសពីមុនមកទេ ។ កូនក្តីខ្លួននឹងមិនបង្កការលំបាកណាមួយដល់ការស៊ើបសួរនោះទេ ហើយនឹងចូលខ្លួនតាមការកោះហៅពីតុលាការគ្រប់នីតិវិធី មិនរត់គេចខ្លួនទៅណានោះទេ ។ ហេតុនេះ សូមក្រុមប្រឹក្សាសម្រេចដោះលែងកូនក្តីខ្លួនឲ្យនៅក្រៅឃុំតាមច្បាប់ ។

-មេធាវី [redacted] ឧស្សាហ៍ ការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តោ បានកត់សម្គាល់ប្តឹងសុំថា កូនក្តីរបស់ខ្លួនបានបញ្ជាក់ថា កន្លងមកកាលពីឆ្នាំ២០០៦ អំឡុងខែមិថុនា ឈ្មោះ [redacted] គួន បានមកខ្ចីចងការប្រាក់ពីកូនក្តីខ្លួនចំនួន ២៥០,០០០(ម្ភៃប្រាំម៉ឺន)រៀល ។ តាមចម្លើយកូនក្តីខ្លួនបានឆ្លើយនៅអធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្តាល គិតពីថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៧ គឺខ្លួនបានពិនិត្យមើលកំណត់ហេតុឃើញថា ឈ្មោះ [redacted] គួន ភេទស្រីពិតជាមានចេតនាឆបោកប្រាក់ ពីកូនក្តីរបស់ខ្លួនពិតប្រាកដមែន ។ ហេតុនេះ ខ្លួ



Scanned by CamScanner

សូមសំណូមពរដល់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាធ្វើការតម្កល់ដីកាសម្រេចឲ្យឃុំខ្លួនលើឈ្មោះ [redacted]គួន របស់សាលាដំបូងខេត្តកណ្តាល ទុកនៅដដែលដោយក្តីអនុគ្រោះ ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនត្រូវចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការប្តឹងសុំ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានកត់សម្គាល់ប្តឹងសុំរបស់មេធាវី

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងរួច

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់

## សំអាងហេតុ

១-ពាក្យបណ្តឹងឧទ្ធរណ៍របស់មេធាវី [redacted] លឹមហួរ ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted]គួន ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៧ ដែលបានដាក់មកសាលាឧទ្ធរណ៍ផ្ទាល់ដើម្បីដោះលែងកូនក្តីខ្លួន បានធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។ ហេតុដូច្នេះ សភាស៊ើបសួរនៃសាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន យោងតាមមាត្រា ២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនត្រូវចោទឈ្មោះ [redacted] គួន ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទឆបោក ត្រង់មាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិព្រះប្រសប់ ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៧ ហើយមេធាវី [redacted]លឹមហួរ ការពារសិទ្ធិឲ្យជនត្រូវចោទត្រូវឈ្មោះ[redacted]គួន បានដាក់ពាក្យសុំឲ្យកូនក្តីនៅក្រៅឃុំនៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៧ ទៅចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល តែចៅក្រមមិនបានសម្រេច ។ ហេតុដូចនេះ សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ពិភាក្សា និងសម្រេចផ្អែកតាមមាត្រា ២១៧ កថាខណ្ឌ ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការបានកត់សម្គាល់ប្តឹងសុំថា បណ្តឹងឧទ្ធរណ៍របស់មេធាវី[redacted]លឹមហួរ ការពារសិទ្ធិឲ្យជនត្រូវចោទត្រូវឈ្មោះ [redacted] គួន បានធ្វើឡើងត្រឹមត្រូវតាមមាត្រា ២១៧ នៃនីតិវិធីព្រហ្មទណ្ឌ ។ ជនត្រូវចោទរងបទចោទប្រកាន់ជាបទល្មើសមជ្ឈិម មានការឃុំខ្លួនរយៈពេលជាង ៥(ប្រាំ)ខែហើយលើសរយៈពេលឃុំខ្លួនក្នុងមាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌហើយ ។ សំណុំរឿងមិនមានការលំបាកស៊ើបសួរទេ ។ ហេតុដូចនេះ គប្បីក្រុមប្រឹក្សាសម្រេចតាមច្បាប់ ។

៤-តាមសេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] លឹមហួរ ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted] គួន បានកត់សម្គាល់ប្តឹងសុំថា មូលហេតុនៃការសុំដោះលែងក្រៅឃុំគឺថា ជនត្រូវចោទឈ្មោះ [redacted] គួន មានទីលំនៅមុខរបរត្រឹមត្រូវ មិនមានចេតនាគេចវេសទេគឺថានៅថ្ងៃកើតហេតុបានគេទូរស័ព្ទខ្ចីលុយ ហើយបានឲ្យទៅយកស្រាប់តែប៉ូលីសឃាត់ខ្លួនតែម្តង ។ រឿងនេះជាវិវាទកិច្ចសន្យាខ្ចីប្រាក់ ដើមបណ្តឹងមិនទាន់ដឹងចំនួនប្រាក់ជំពាក់ច្បាស់



Scanned by CamScanner

ពាក់ព័ន្ធនឹងបណ្តឹង ចាប់តាំងពីឃុំខ្លួនរហូតដល់រយៈពេលជាង ៥(ប្រាំ)ខែ ដោយមិនមានធាតុផ្សំបទល្មើសព្រហ្មទណ្ឌ ដែលខុសគោលការណ៍នៃការឃុំខ្លួន ត្រង់មាត្រា ២០៣ និងមាត្រា ២០៥ នៃនីតិវិធីព្រហ្មទណ្ឌ ។ រឿងនេះ ការស៊ើបសួរមានភាពជឿនលឿន ដោយបានសាកសួរស្តាប់ចម្លើយជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ ជនត្រូវចោទមិនអាចរត់គេចខ្លួនទេ មិនបង្កការលំបាកដល់ការស៊ើបសួរទេ គ្មានភស្តុតាងដែលអាចទៅបំផ្លាញទេ ហើយខ្លួនសន្យាថា នឹងចូលមកបង្ហាញខ្លួនរាល់ពេលមានការកោះហៅរបស់តុលាការ ។ ហេតុដូចនេះ សូមក្រុមប្រឹក្សាសម្រេចដោះលែងឈ្មោះ [redacted] គួន ឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន តាមនីតិវិធី ។

៥-តាមសេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ឧស្សាហ៍ ការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គោ បានកត់សម្គាល់ឃើញថា រឿងនេះការខ្ចីប្រាក់មានរយៈពេលជាង ១០ឆ្នាំហើយ ។នៅថ្ងៃចាប់ខ្លួនជនត្រូវចោទបានទូរស័ព្ទមកបន្លំសម្លេងថាតែដើម្បីខ្ចីប្រាក់ ។ ជនត្រូវចោទគេចវេសរហូត មិនព្រមសងប្រាក់ សន្យាថ្ងៃនេះថ្ងៃនោះ តែមិនបានអនុវត្ត ។ ហេតុនេះ សុំឲ្យក្រុមប្រឹក្សាសម្រេចរក្សាការឃុំខ្លួនជាបណ្តោះអាសន្នសិន ។

៦-ក្រោយពេលពិភាក្សាដេញដោល ស្តាប់អំណានចម្លើយជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងស្តាប់សេចក្តីថ្លែងការណ៍របស់មេធាវី និងពិនិត្យឯកសារមានក្នុងសំណុំរឿងរួច បានបញ្ជាក់ឲ្យដឹងថា ជនត្រូវចោទត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនមានរយៈពេលជាង ០៥(ប្រាំ)ខែ ដែលរយៈពេលនេះខុសទៅនឹងមាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ហេតុនេះ ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជំនួសឲ្យការឃុំខ្លួន ជាវិធានការណ៍មួយសមរម្យព្រោះថា មូលហេតុនៃការឃុំខ្លួនដែលមានចែងនៅត្រង់មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លែងជាការចាំបាច់ទៀតហើយ បើធៀបទៅនឹងគោលការណ៍សេរីភាពត្រង់មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៧-គោលការណ៍សេរីភាពត្រង់មាត្រា ២០៣ ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការត្រង់មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងសារាចរស្តីពី ការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ លេខ ០១កយ.សរ/១៤ ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៤ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គប្បីលើកមកពិចារណាក្នុងករណីនេះ ។

៨-ជាសរុបពីចំណុច ៣ ដល់ចំណុច ៧ នៃសំអាងហេតុខាងលើ ក្រុមប្រឹក្សាយល់ឃើញថា ការស៊ើបសួររឿងក្តីនេះមានភាពជឿនលឿន ហើយលទ្ធផលនៃការស្រាវជ្រាវមានការវិវឌ្ឍន៍ ។ ប្រសិនបើដោះលែងជនត្រូវចោទឈ្មោះ [redacted] គួន ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន មិនមានការបារម្ភថា នឹងមានឥទ្ធិពល និងប៉ះពាល់ដល់នីតិវិធីស៊ើបសួររបស់តុលាការទេ ។

**ហេតុដូចនេះ វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងរបស់មេធាវី [redacted] លីមហួរ ការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ [redacted] គួន ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៧ ទុកជាត្រឹមត្រូវតាមទម្រង់ និងតាមច្បាប់



Scanned by CamScanner

២-សម្រេចដោះលែងជនត្រូវចោទឈ្មោះ [redacted] គួន (អត្តសញ្ញាណមាននៅក្នុងសំណុំរឿងស្រាប់) ពីបទ ឆបោក ត្រង់មាត្រា ៣៧៧ មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិព្រះប្រសប់ ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៧ ។

៣-សម្រេចដាក់ជនត្រូវចោទឈ្មោះ [redacted] គួន ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនូវចំណុចដូចខាងក្រោម៖

ក-មិនត្រូវចាកចេញពីព្រះរាជាណាចក្រកម្ពុជា ។

ខ-មិនត្រូវផ្លាស់ប្ដូរទីលំនៅដោយគ្មានការអនុញ្ញាតពីតុលាការ ។

គ-ត្រូវចូលទៅបង្ហាញខ្លួននៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល រៀងរាល់ថ្ងៃទី ០១ នៃខែនីមួយៗ ។

ឃ-ត្រូវឆ្លើយតបទៅនឹងការកោះហៅរបស់តុលាការ ។

៤-បង្គាប់ឲ្យលោកប្រធានមន្ទីរឃុំឃាំង ឬពន្ធនាគារខេត្តកណ្ដាលធ្វើការដោះលែងឈ្មោះ [redacted] គួន ចេញពីពន្ធនាគារជាបន្ទាន់ ប្រសិនឈ្មោះនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតទេ ។

-សាលដីកានេះប្រកាសជាអសាធារណៈនៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៧ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា [redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។
ភ្នំពេញ ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៧
ក្រឡាបញ្ជី

[redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សា

[redacted]



Scanned by CamScanner